មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:[illegible]

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ.កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីអប់រំ ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច កសាង និងអភិវឌ្ឍន៍វិស័យអប់រំ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

-ឯកឧត្តម បណ្ឌិត **អ៊ុំ ថុន** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-ឯកឧត្តម បណ្ឌិត **ពេជ្រ តីរ្យ** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

២-ឯកឧត្តម បណ្ឌិត **ឡោ សុជាតិ** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

៣-លោក **អ៊ុំ សុគន្ធ** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៣៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីដឹកនាំ និងបុគ្គលិកសិក្សានៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ចំនួន ៧៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច កសាងនិងអភិវឌ្ឍន៍វិស័យអប់រំ ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសការងារ :

១-លោក	**សេង**	**ប៊ុនឡើន**	សាកលវិទ្យាធិការរង
២-ឯកឧត្តម បណ្ឌិត	**គីម**	**រ័ត្នវិសិដ្ឋ**	នាយកសាលាក្រោយឧត្តម
៣-លោក	**ស៊ូ**	**ផល្លា**	ព្រឹទ្ធបុរសមហាវិទ្យាល័យគ្រប់គ្រង
៤-លោកស្រី	**វ៉ា**	**បូណាវ៉ា**	ព្រឹទ្ធបុរសមហាវិទ្យាល័យគណនេយ្យហិរញ្ញវត្ថុ
៥-លោក	**នៅ**	**សារ៉េត**	ព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រ
៦-លោក	**ជ័យ**	**ទថ់**	ព្រឹទ្ធបុរសមហាវិទ្យាល័យទេសចរណ៍
៧-លោកស្រី	**ស៊ឹម**	**សុវិចារណ៍**	ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច
៨-លោក	**ឆាយ**	**ផាវ**	ព្រឹទ្ធបុរសមហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន
៩-លោក	**ក្រូច**	**សុផាន់ណា**	នាយកផ្នែកបុគ្គលិក រដ្ឋបាល និងគណនេយ្យ
១០-លោក	**សោ**	**សុផាន់**	នាយកផ្នែកសិក្សា ស្រាវជ្រាវ និងបណ្ណាល័យ
១១-លោក	**ជា**	**ស៊ឿន**	នាយកសាខា បាត់ដំបង

១២-លោក លី សុខហេង នាយករងសាលាក្រោយឧត្តម
១៣-លោក គង សុវណ្ណារ៉ា ព្រឹទ្ធបុរសរង មហាវិទ្យាល័យគ្រប់គ្រង
១៤-លោកស្រី ជា សោភ័ណ នាយករងផ្នែកគណនេយ្យ រដ្ឋបាល និង បុគ្គលិក
១៥-លោកស្រី អ៊ុំ សារឿន នាយករងផ្នែកសិក្សា ស្រាវជ្រាវ និង បណ្ណាល័យ
១៦-លោកស្រី ម៉ាន ម៉ុនដេន នាយករងផ្នែកសិក្សា ស្រាវជ្រាវ និង បណ្ណាល័យ
១៧-លោក អ៊ុក ផុន ប្រធានការិយាល័យបុគ្គលិក

ខ.មេដាយប្រាក់ការងារ :

១-លោក នូ សេដ្ឋា សាកលវិទ្យាធិការរង
២-លោកស្រី កែ ចន្ទណារិន ព្រឹទ្ធបុរសរងមហាវិទ្យាល័យគ្រប់គ្រង
៣-លោក កែវ គុយលី ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច
៤-លោក ញឹក សុគន្ធ ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច
៥-លោក ហេង សុភាព ព្រឹទ្ធបុរសរងមហាវិទ្យាល័យទេសចរណ៍
៦-លោក កែវ សុគន្ធ ព្រឹទ្ធបុរសរងមហាវិទ្យាល័យទេសចរណ៍
៧-លោក អុប ម៉ុនឈាន ព្រឹទ្ធបុរសរងមហាវិទ្យាល័យហិរញ្ញវត្ថុ
៨-លោក គុយ គុសល ព្រឹទ្ធបុរសរងមហាវិទ្យាល័យហិរញ្ញវត្ថុ
៩-លោក អ៊ួយ វីរដែល ព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ
១០-លោក មាស មុន្នី ព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ
១១-លោក ហ៊ុង រតនា ព្រឹទ្ធបុរសរងមហាវិទ្យាល័យព័ត៌មានវិទ្យា
១២-លោកស្រី ឃិន ចាន់ថា ព្រឹទ្ធបុរសរងមហាវិទ្យាល័យព័ត៌មានវិទ្យា
១៣-លោក តាន់ សារឿន នាយករងសាលាក្រោយឧត្តម
១៤-លោក យី សំភី នាយករងផ្នែកបុគ្គលិក រដ្ឋបាល និងគណនេយ្យ
១៥-លោក ជ័យ សុវណ្ណារិទ្ធ នាយករងសាខាបាត់ដំបង
១៦-លោក ឡេង គីមហុក នាយករងសាខាបាត់ដំបង
១៧-លោក សុខ ស៊ាង ប្រធានមជ្ឈមណ្ឌលភាសាបរទេស
១៨-លោក កែម គីម ប្រធានការិយាល័យសិក្សា និងអប់រំបន្ត
១៩-លោក ទុំណា សហៈ ប្រធានការិយាល័យរដ្ឋបាល
២០-លោកស្រី ជៀស វណ្ណៈជឿន ប្រធានអាសនៈផ្នែកគ្រប់គ្រង
២១-លោកស្រី ជីវ សុខៈចេង ប្រធានការិយាល័យគណនេយ្យ
២២-លោក និន ទ្រី ប្រធានការិយាល័យស្រាវជ្រាវ
២៣-លោក សួន ឃុង ប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ
២៤-លោក នួច ឃួត ប្រធានបណ្ណាល័យ
២៥-លោកស្រី អ៊ុក ដារ៉ា ប្រធានលេខាធិការដ្ឋាន
២៦-លោកស្រី ឈឿង ចរិយា ប្រធានអាសនៈផ្នែកម៉ាឃីតធីង
២៧-លោក អ៊ុង ទាសនា ប្រធានអាសនៈផ្នែកទេសចរណ៍

២៨-លោកស្រី	ស្រី ផាណារិន	ប្រធានអាសនៈផ្នែកបដិសណ្ឋារកិច្ច
២៩-លោក	ហោយ ចំរើន	ប្រធានអាសនៈផ្នែកសេដ្ឋកិច្ចទូទៅ
៣០-លោកស្រី	អ៊ុត សំម៉ុណ្ណារី	ប្រធានអាសនៈផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍
៣១-លោក	ឈុន វ៉ាឌី	ប្រធានអាសនៈផ្នែកកុំព្យូទ័រ រចនាប្លង់
៣២-លោក	ឈុន វ៉ា	ប្រធានអាសនៈផ្នែកកុំព្យូទ័រ គ្រប់គ្រងព័ត៌មានវិទ្យា
៣៣-លោក	សៅ ឡាយ	ប្រធានអាសនៈផ្នែកច្បាប់សាធារណៈ
៣៤-លោក	ម៉េង ពុទ្ធារ៉ា	ប្រធានអាសនៈផ្នែកច្បាប់ឯកជន
៣៥-លោក	សៀម មុនីលក្ខណ៍	ប្រធានអាសនៈផ្នែកគណនេយ្យ
៣៦-លោក	កុល បូរ៉ែន	ប្រធានអាសនៈផ្នែកធនាគារ
៣៧-លោក	អ៊ា ស៊ុះហេង	ប្រធានអាសនៈផ្នែកឆ្នាំសិក្សាមូលដ្ឋាន

គ-មេដាយសំរឹទ្ធការងារ :

១-លោក	ឈិត សុវណ្ណ	អនុប្រធានការិយាល័យរដ្ឋបាល
២-លោកស្រី	ប៉ុល ភក្ដីនី	អនុប្រធានការិយាល័យស្រាវជ្រាវ
៣-លោកស្រី	ឡើន គីមទូច	អនុប្រធានការិយាល័យគណនេយ្យ
៤-លោកស្រី	ប៉ុង ពុទ្ធី	អនុប្រធានការិយាល័យសិក្សា និងអប់រំបន្ត
៥-លោក	ម៉ឿង ឡា	អនុប្រធានមជ្ឈមណ្ឌលភាសាបរទេស
៦-លោកស្រី	ឈិន រេង	អនុអាសនៈផ្នែកគ្រប់គ្រង
៧-លោកស្រី	អ៊ុង វណ្ណដាល័យ	អនុអាសនៈផ្នែកម៉ាឃីតធីង
៨-លោកស្រី	ស៊ឹម សុខខេង	អនុអាសនៈផ្នែកទេសចរណ៍
៩-លោកស្រី	នេត្រា សុវណ្ណ	អនុអាសនៈផ្នែកបដិសណ្ឋារកិច្ច
១០-លោកស្រី	អ៊ុត សារិន	អនុអាសនៈផ្នែកសេដ្ឋកិច្ចទូទៅ
១១-លោក	សយ សុខន	អនុអាសនៈផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍
១២-លោក	ទុំ សុផល	អនុអាសនៈផ្នែកកុំព្យូទ័រ គំនូររចនាប្លង់
១៣-លោក	ទឹម សុគុន	អនុអាសនៈផ្នែកកុំព្យូទ័រគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា
១៤-លោកស្រី	ជុន នួននិមល	អនុអាសនៈផ្នែកច្បាប់សាធារណៈ
១៥-លោកស្រី	សួន នាងឆវី	អនុអាសនៈផ្នែកគណនេយ្យ
១៦-លោក	អ៊ុង ម៉ារឌី	អនុអាសនៈផ្នែកធនាគារ
១៧-លោក	លឹម យូរសេង	អនុអាសនៈផ្នែកឆ្នាំសិក្សាមូលដ្ឋាន
១៨-លោកស្រី	ស៊ុក ឡូច	អនុប្រធានបណ្ណាល័យ
១៩-លោកស្រី	កុល ស៊ីណា	អនុប្រធានលេខាធិការដ្ឋាន
២០-លោក	មុត ម៉ិន្នា	អនុប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ
២១-លោក	ឡូច សម្បត្តិ	អនុប្រធានការិយាល័យបុគ្គលិក
២២-លោក	សួង ភន	បុគ្គលិកការិយាល័យរដ្ឋបាល
២៣-លោកស្រី	ហង់ សោភ័ណ	បុគ្គលិកការិយាល័យរដ្ឋបាល

២៤-លោក **ចាន់ ម៉ុនះថត** បុគ្គលិកការិយាល័យសិក្សា
២៥-លោកស្រី **ហេង សំអូន** បុគ្គលិកលេខាធិការដ្ឋាន

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ [illegible]

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក DO KYU HYUNG President of K.C.L.S Co., Ltd នៃសាធារណរដ្ឋកូរ៉េ ដែលបានឧបត្ថម្ភម៉ាស៊ីនកុំព្យូទ័រ ចំនួន១០គ្រឿង ម៉ាស៊ីនព្រីនធ័រ ចំនួន១០គ្រឿង សំលៀកបំពាក់ ៧០សម្រាប់ ព្រមទាំងឧបត្ថម្ភគ្រូបង្ហាត់ម្នាក់ ក្នុងរយៈពេល ០១ឆ្នាំ ចំណាយអស់ទឹកប្រាក់ សរុបចំនួន ១២.០០០ ដុល្លារអាមេរិក ជូនអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨០ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

៣៥

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ចូ ឌ្យូ ចាន់** (*Cho Kyu-Chan*) តំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (*KOICA*) នៅភ្នំពេញ ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ និងជួយអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា តាមរយៈការផ្តល់ជំនួយនិងប្រាក់កម្ចីនានា។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ២៧ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៦១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមជួយកសាង សាលាឆាន់ របង និងស្តារស្រះទឹក នៅក្នុងពុទ្ធសីមាវត្តតាំងកសាងខាងត្បូង សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

១-ព្រះតេជគុណ	**នូ សារិន**	ចៅអធិការវត្តតាំងកសាងខាងត្បូង	បច្ច័យចំនួន ២១.៣០០ ដុល្លារ
២-លោកស្រី	**ខូ យក់ឡាន**		ថវិកាចំនួន ១៦.៥០០ ដុល្លារ
៣-លោក	**គ្រួច ផាន**	អភិបាលខណ្ឌដង្កោ	ថវិកា ចំនួន ១៣.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧០២ .អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ ..

ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១-លោកឧត្តមសេនីយ៍ទោ **គឹម ចាន់នី** អត្តលេខ ០០៦៧ ពីប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ។

២-លោកឧត្តមសេនីយ៍ត្រី **សូត ធី** អត្តលេខ ០៤០៩ ពីអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ទៅជាប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ ។

មាត្រា ២ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ......៩០៣......អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន០២រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាង អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ នៅសាលាឧបសម្ព័ន្ធ គ្រពាំងអំពិល ឃុំពន្សាំង ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

ក. មេដាយមាសស្ថាបនាជាតិ :

-Mr. KUWAHARA EIJI សប្បុរសជន ជប៉ុន បានឧបត្ថម្ភថវិកាចំនួន ២០.០០០ ដុល្លារ

ខ. មេដាយសំរឹទ្ធស្ថាបនាជាតិ :

-លោក **ស៊ុន គីមលី** សប្បុរសជននៅក្រុងភ្នំពេញ បានឧបត្ថម្ភថវិកាចំនួន ១.៨០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។ ✗✗

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.162

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨០៤ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១៧គ្រឿង ប្រគេន និងជូនសប្បុរសជន ចំនួន១៧រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកា ចូលរួមជួយកសាង ពុទ្ធិកសកលវិទ្យាល័យមិត្តភាពមជ្ឈមណ្ឌលព្រះពុទ្ធសាសនាថ្ងៃអាទិត្យ នៅក្នុងសង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

ក. មេដាយមាសស្ថាបនាជាតិ :

១-ភិក្ខុវជិរគុត្តោ	**សម ស៊ុំឈាន**		បច្ច័យចំនួន ១៨.៥៦៥ ដុល្លារ
២-ភិក្ខុ	**គីម ចាន់ឈាន**		បច្ច័យចំនួន ១៧.៥០៨ ដុល្លារ
៣-ភិក្ខុ	[illegible] **អ៊ី**	សប្បុរសជននៅប្រទេសចិន	បច្ច័យចំនួន ១៧.២០០ ដុល្លារ
៤-ព្រះធម្មឃោសាចារ្យ	**អ៊ុក វ៉ន**		បច្ច័យចំនួន ១៦.២១០ ដុល្លារ
៥-លោក	**តឹម ទិបុល**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១៦.១៣០ ដុល្លារ
៦-លោក	**អ៊ុក ធីម**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១៥.០០៩ ដុល្លារ
៧-ឧបាសិកា	**សៅ លីន**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១៤.០០០ ដុល្លារ
៨-ឧបាសក	**ស៊ីវ មណ្ណ**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១៣.២០០ ដុល្លារ
៩-ឧបាសក	**ឌូ ម៉ៅ**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១២.២០៥ ដុល្លារ
១០-ឧបាសក	**តោង គុណា**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១២.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-ភិក្ខុ	**មួង សារឿន**	សប្បុរសជន	ថវិកា ចំនួន ៦.០០៦ ដុល្លារ
២-ឧបាសក	**ឡុក ត្រី**	សប្បុរសជន	ថវិកា ចំនួន ៩.១០០ ដុល្លារ
៣-ឧបាសក	**ឆាន់ សាវី**	សប្បុរសជន	ថវិកា ចំនួន ៧.០២០ ដុល្លារ
៤-ឧបាសក	**ម៉ា ចាន់**	សប្បុរសជន	ថវិកា ចំនួន ៩.២០០ ដុល្លារ
៥-ឧបាសិកា	**អ៊ុំ សុខុម**	សប្បុរសជន	ថវិកា ចំនួន ៧.១១៥ ដុល្លារ
៦-កញ្ញា	**អៀង ធារិយា**	សប្បុរសជន	ថវិកា ចំនួន ៨.០០០ ដុល្លារ
៧-លោក	**លឹម សុជាតិ**	សប្បុរសជន	ថវិកា ចំនួន ៥.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Ps-205

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧០៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៤រូប ដែលបានជួយឧបត្ថម្ភថវិកាសំរាប់សាងសង់អគារសិក្សា ០២ខ្នង ក្នុង០១ខ្នងមាន ០៣បន្ទប់ នៅសាលាបឋមសិក្សាខ្ទង់កោះ ភូមិកោះចិន ក្នុងស្រុកពញាឮ ខេត្តកណ្តាល សរុបជាទឹកប្រាក់ទាំងអស់មានចំនួន ៩៤.៤៥០.២៥ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **Pius Fisher** ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំប្រទេសកម្ពុជា

២-លោក **Detlef Gutjahr** សមាជិកគណៈកម្មការប្រតិបត្តិសមាគម **TKG**

៣-លោក **Mamoru NANAMURA** ម្ចាស់អំណោយ តាមរយៈអង្គការ **FIDR**

៤-លោក **ជោ គឹមឈេង** នាយកអង្គការកែច្នៃសំរាមកម្ពុជា (**COMPED**)

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនអស់លោក ចំនួន ១៥ នាក់ ជាសមាជិកគណៈកម្មការសាងសង់អាគារសាលាខេត្តបាត់ដំបង ដែលបានខិតខំប្រឹងប្រែង ទទួលខុសត្រូវខ្ពស់ សំរេចបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោមនេះ :

ក/ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

១	លោក ឆាត់ ឈឿម	សមាជិកគណៈកម្មការសាងសង់អាគារសាលាខេត្តបាត់ដំបង
២	លោក ស៊េខ សខ់ងឹម	សមាជិកគណៈកម្មការសាងសង់អាគារសាលាខេត្តបាត់ដំបង

ខ/ មេដាយមុនិសារាភ័ណ្ឌ ថ្នាក់ សេនា

១	លោក ខួន រតនៈ	ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង
២	លោក អ៊ុយ លីម	នាយក្រុមហិរញ្ញវត្ថុសាលាខេត្តបាត់ដំបង
៣	លោកស្រី សុខ សុខុន	សមាជិកគណៈកម្មការសាងសង់អាគារសាលាខេត្តបាត់ដំបង

គ/ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១	លោក ពាន ណារិទ្ធ	អគ្គលេខាធិការរង សាលាខេត្តបាត់ដំបង
២	លោក នុត ប៊ុណ្ណា	នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តបាត់ដំបង

៣	លោក ឌឹម ដុនេត្រ្ត	អភិបាលរងស្រុកបាត់ដំបង ខេត្តបាត់ដំបង
៤	លោក នុំ ដារ៉ី	អនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង
៥	លោក នួន សុភា	ស្ថាបត្យករ សមាជិកគណៈកម្មការសាងសង់អាគារសាលាខេត្តបាត់ដំបង
៦	លោក ជា សទ្ធាសេរីវឌ្ឍន៍	សមាជិកគណៈកម្មការសាងសង់អាគារសាលាខេត្តបាត់ដំបង
៧	លោក សៀង ឯមវុស្ថី	ស្ថាបត្យករ គូប្លង់អាគារសាលាខេត្តបាត់ដំបងថ្មី
៨	លោក ជៀង ធន	អ្នកបកប្រែទេស
៩	លោក ឯម សុគន្ធី	អ្នកបកប្រែទេស
១០	លោក ម៉ុត សារិទណ្ណា	អ្នកបកប្រែទេស

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤០១ អនក.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនអស់លោក ចំនួន ០២ នាក់ ជាសមាជិកគណៈកម្មការស្រាវជ្រាវ ចងក្រងប្រវត្តិខេត្តបាត់ដំបង ដែលបានខិតខំប្រឹងប្រែង ទទួលខុសត្រូវខ្ពស់ សំរេចបានលទ្ធផលល្អ ក្នុងការស្រាវជ្រាវចងក្រងប្រវត្តិខេត្តបាត់ដំបង សំរាប់ជាកម្រងឯកសារប្រវត្តិសាស្ត្រ ដល់ខ្មែរជំនាន់ក្រោយ ដូចមានរាយនាមខាងក្រោមនេះ :

ក/ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

១ លោក **នុប តាន់លាន** ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង

ខ/ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១ លោក **ម៉ុំ វ្រារាត** អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤៣...ក្រ.ក.ច

សេចក្ដីសម្រេច

ស្ដីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួង ដើម្បីត្រួតពិនិត្យលើលទ្ធផលនៃការសិក្សាស្រាវជ្រាវធនធានរ៉ែរបស់ក្រុមហ៊ុនទាំងអស់ ដែលបានទទួលគោលការណ៍រួចហើយ ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនុក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៥
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្ដីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងអនុក្រឹត្យ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃ ក.អ.ក "គ.វ.ក" នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥

សម្រេច

ប្រការ១: បង្កើតក្រុមអធិការកិច្ចអន្តរក្រសួង ដើម្បីត្រួតពិនិត្យលើលទ្ធផលនៃការសិក្សាស្រាវជ្រាវធនធានរ៉ែ របស់ក្រុមហ៊ុនទាំងអស់ ដែលបានទទួលគោលការណ៍រួចហើយ ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដែលមានសមាសភាព ដូចខាងក្រោម :

១- ឯកឧត្តម **ច្រាក់ ហេម**	រដ្ឋលេខាធិការក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច	ប្រធាន
២- ឯកឧត្តម **ជា ស៊ាងហុង**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	អនុប្រធាន
៣- ឯកឧត្តម **សួន សិទ្ធី**	អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា	សមាជិក
៤- ឯកឧត្តម **ញាណ ឡេង**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥- ឯកឧត្តម **ឆា ជុម**	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៦- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧- ឯកឧត្តម **មួង សៅខន**	អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
៨- ឯកឧត្តម **អ៊ិត ណូឌី**	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៩- ឯកឧត្តម **គ្រួច ម៉ុនលី**	អគ្គនាយក ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច	សមាជិក
១០- ឯកឧត្តម **សុខ ឡេង**	អគ្គនាយក នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១១- គ្រប់អភិបាលខេត្ត/ក្រុងពាក់ព័ន្ធ		សមាជិក
១២- លោក **យុន ហេង**	អនុប្រធាននាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត នៃក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា	សមាជិក
១៣- លោក **សេង សុចិន្តា**	អនុប្រធាននាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ នៃក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា	លេខាធិការ

សមាជិកក្រុមអធិការកិច្ចទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

ប្រការ២: ក្រុមអធិការកិច្ចអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

- ចុះពិនិត្យដល់ទីកន្លែង សំដៅស្វែងយល់ពីការសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុនរ៉ែទាំងអស់ ដែលបានទទួលគោលការណ៍រួចហើយ ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដោយចាប់ផ្តើមមុនគេពីក្រុមហ៊ុនរ៉ែនៅតំបន់ស្រុករវៀង ខេត្តព្រះវិហារ។
- ស្វែងយល់ពីមូលហេតុនៃការយឺតយ៉ាវក្នុងការប្រគល់ទីតាំងរ៉ែគ្មានសកម្មភាព ឬមានសកម្មភាពតិចតួចជូនក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group.នេះ តាមការសំរេចកន្លងមករបស់សម្តេចសហប្រធាន"ក.អ.ក" ដើម្បីមានវិធានការជំរុញការអនុវត្តអោយបានឆាប់ក្នុងទិសដៅជួយបង្កលក្ខណៈសម្បត្តិអោយក្រុមហ៊ុននេះ អាចជំរុញការវិនិយោគជាកញ្ចប់(រោងចក្រស្លដែក-រោងចក្រផលិតអគ្គិសនី-សាងសង់ផ្លូវរថភ្លើង-សាងសង់កំពង់ផែ.....) បាន។
- រាយការណ៍ពីលទ្ធផល នៃការត្រួតពិនិត្យជាក់ស្តែង នៅតាមការដ្ឋានស្រាវជ្រាវរ៉ែ របស់ក្រុមហ៊ុននីមួយៗ ជូន"ច្រកចេញ-ចូលតែមួយ" របស់"ក.អ.ក" ដើម្បីពិនិត្យ និងផ្តល់មតិជូនរាជរដ្ឋាភិបាលធ្វើការសំរេច។

ប្រការ៣: គ្រប់សមាសភាពនៃក្រុមអធិការកិច្ចអន្តរក្រសួង មានសិទ្ធិនាំយកទៅជាមួយ នូវមន្ត្រីបច្ចេកទេសជំនាញ ដោយគ្រាន់តែមានលិខិតឧទ្ទេសនាមពីប្រធានស្ថាប័នរបស់ខ្លួនបន្ថែមប៉ុណ្ណោះ នៅពេលចុះបំពេញបេសកកម្ម។

ប្រការ៤: ក្រុមអធិការកិច្ចអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងកញ្ចប់ថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ។

ប្រការ៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច - រដ្ឋមន្ត្រីក្រសួងបរិស្ថាន - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល - រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - រដ្ឋមន្ត្រីគ្រប់ក្រសួង - គ្រប់ប្រធានស្ថាប័ន - គ្រប់ខេត្ត/ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ១០ ឆ្នាំ ២០០៥

ចៅនាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន"ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន"ក.អ.ក"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៤៤...អនក្រ.បក

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការរៀបចំពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-ឃ្យុងយូ ២០០៦
(Organizing Committee for Angkor-Gyeongju World Cultural Expo 2006)
នៅខេត្តសៀមរាប ឆ្នាំ២០០៦-២០០៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន/ស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់

សំរេច

ប្រការ ១: បង្កើតគណៈកម្មការអន្តរក្រសួង (Organizing Committee) ដើម្បីរៀបចំការតាំងពិព័រណ៍វប្បធម៌ពិភព-លោក អង្គរ-ឃ្យុងយូ ២០០៦ (Angkor-Gyeongju World Cultural Expo 2006) នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តម **សុខ អាន**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២- អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ប៉ណ្ណារ៉ា ស៊ីរីវុឌ្ឍ**	រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	អនុប្រធាន
៣- ឯកឧត្តម **ឡាយ ប្រហាស**	រដ្ឋមន្ត្រីក្រសួងទេសចរណ៍	អនុប្រធាន
៤- ឯកឧត្តម **សេខ លឹមនៅ**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៥- ឯកឧត្តម **ញ៉ឹ សុខា**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៦- ឯកឧត្តម **ថោង ខុន**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធានអចិន្ត្រៃយ៍
៧- ឯកឧត្តម **មិន ឃិន**	រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា និងជាអគ្គលេខាធិការគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ	សមាជិក
៨- ឯកឧត្តម **ឌុច គៀន**	រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
៩- ឯកឧត្តម **ម៉ៅ អាយុទ្ធ**	រដ្ឋលេខាធិការក្រសួងពត៌មាន	សមាជិក
១០- ឯកឧត្តម **ស្វ ម៉ារ៉ា**	អគ្គលេខាធិការ អាជ្ញាធរជាតិទេសចរណ៍	សមាជិក

១១- ឯកឧត្តម	**ម៉ែន ស៊ីម៉ន**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ	សមាជិក
១២- ឯកឧត្តម	**ស៊ឹម សុន**	អភិបាលខេត្តសៀមរាប	សមាជិក
១៣-ឯកឧត្តម	**នឹម ចំន្ទសារា**	អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
១៤- ឯកឧត្តម	**ទី គាយឺ**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១៥- ឯកឧត្តម	**សយ សុខាន់**	អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	សមាជិក
១៦- ឯកឧត្តម	**សៅ សុខា**	មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
១៧- ឯកឧត្តម	**នេត សាវឿន**	អគ្គស្នងការរងនគរបាលជាតិ	សមាជិក
១៨-ឯកឧត្តម	**ប៊ុន ណារិទ្ធ**	អគ្គនាយកអាជ្ញាធរអប្សរា	សមាជិក និងជាប្រធានលេខាធិការដ្ឋាន
១៩-ឯកឧត្តម	**អ៊ុក សូមេត្ថ**	អគ្គនាយករងអាជ្ញាធរអប្សរា	សមាជិក និងជាអនុប្រធានលេខាធិការដ្ឋាន
២០-ឯកឧត្តម	**ម៉ី ម៉ារ៉ាឌី**	អគ្គនាយករងអាជ្ញាធរអប្សរា	សមាជិក និងជាអនុប្រធានលេខាធិការដ្ឋាន

ប្រការ ២: គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម:

- សហការជាមួយភាគីកូរ៉េ ដើម្បីរៀបចំពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-ឃ្យុងយូ ២០០៦-២០០៧ ការសំដែងសិល្បៈ សកម្មភាព និងទស្សនីយភាពផ្សេងៗ អោយបានជោគជ័យល្អប្រសើរ
- សហការជាមួយផ្នែកឯកជន ដើម្បីរៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបំរើអោយព្រឹត្តិការណ៍នេះ និងធ្វើការឃោសនា និងផ្សព្វផ្សាយអំពីព្រឹត្តិការណ៍នេះអោយបានទូលំទូលាយ ទាំងក្នុងប្រទេស និងក្រៅប្រទេស
- រៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សណ្តាប់ធ្នាប់ អនាម័យ នៅទីក្រុងសៀមរាប អោយបានស្អាតល្អ ដើម្បីទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- រៀបចំសំរួលការធ្វើដំណើរ និងទទួលស្វាគមន៍គណៈប្រតិភូ និងភ្ញៀវទេសចរដែលមកចូលរួមក្នុងព្រឹត្តិការណ៍នេះអោយបានល្អ
- បូកសរុបចំណូល និងចំណាយ ព្រមទាំងរាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល

ប្រការ ៣: គណៈកម្មការមានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញនានា តាមតំរូវការចាំបាច់របស់ខ្លួន ។

ប្រការ ៤: ប្រធានគណៈកម្មការត្រូវបង្កើតលេខាធិការដ្ឋាន ដែលជាសេនាធិការរបស់ខ្លួន មានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៥: គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦: សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ ៧: គណៈកម្មការនេះត្រូវចប់ភារកិច្ច និងត្រូវរំសាយជាស្វ័យប្រវត្តិ នៅពេលចប់ព្រឹត្តិការណ៍នេះ ។

ប្រការ ៨: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធានអគ្គនាយកអាជ្ញាធរអប្សរា ប្រធានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ សាលាខេត្តសៀមរាប ក្រសួង ស្ថាប័ន អាជ្ញាធរ ពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោកដែលមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន:
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: [illegible]

សេចក្ដីសំរេច
ស្ដីពី
ការបង្កើតក្រុមការងាររៀបចំក្បួនរថយន្ត Caravan Tour ពីបាងកក-ភ្នំពេញ-ហូជីមិញ ក្នុងក្របខំណ្ឌកិច្ចសហប្រតិបត្តិការ ACMECS និង GMS

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- យោងលិខិតលេខ ១៥៨៩ សជណ-អវ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- តាមការងារចាំបាច់

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតក្រុមការងាររៀបចំក្បួនរថយន្ត Caravan Tour ពីបាងកក-ភ្នំពេញ-ហូជីមិញ ក្នុងក្របខណ្ឌ ACMECS និង GMS ដែលមានសមាសភាព ដូចតទៅ :

១-	ឯកឧត្តម	ថោង ខុន	រដ្ឋលេខាធិការក្រសួងទេសចរណ៍	ប្រធាន
២-	ឯកឧត្តម	ហ៊ុយ តន្ទុលវ៉ា	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៣-	ឯកឧត្តម	សូ ម៉ារ៉ា	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធានប្រចាំការ

ហ.

៤-	ឯកឧត្តម	ឆឹយ រឿន	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥-	ឯកឧត្តម	ងី តាយី	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦-	ឯកឧត្តម ឧត្តមសេនីយ៍	ជុំ សម្ប័ទ	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
៧-	ឯកឧត្តម	សៅ សុកខុន	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
៨-	ឯកឧត្តម	នូ កឿង	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៩-	ឯកឧត្តម	គោស៊ុំ សារឿត	អគ្គនាយកទេសចរណ៍ នៃក្រសួងទេសចរណ៍	សមាជិក
១០-	ឯកឧត្តម	អ៊ុក ស៊ីផាន	អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍	សមាជិក
១១-	ឯកឧត្តម	ទេព ហែន	អគ្គនាយករងអាជ្ញាធរអប្សរា	សមាជិក
១២-	លោក	សរ ចំរុង	អភិបាលរងខេត្តបន្ទាយមានជ័យ	សមាជិក
១៣-	លោក	ចន្ទ័ សុផល	អភិបាលរងខេត្តសៀមរាប	សមាជិក
១៤-	លោក	ហុក សឿន	អភិបាលរងខេត្តកំពង់ធំ	សមាជិក
១៥-	លោក	ម៉េង សួន	អភិបាលរង ខេត្តកំពង់ចាម	សមាជិក
១៦-	លោក	ហេ កាន់	អភិបាលរង ខេត្តកណ្តាល	សមាជិក
១៧-	អ្នកអង្គម្ចាស់	ស៊ីសុវត្ថិ ភានុវត្ត៍	អភិបាលរងរាជធានីភ្នំពេញ	សមាជិក
១៨-	លោក	ប្រាក់ ឡឿន	អភិបាលរងខេត្តព្រៃវែង	សមាជិក
១៩-	លោក	រ៉ុ តិក្ខមុនី	អភិបាលរងទី ៣ ខេត្តស្វាយរៀង	សមាជិក
២០-	លោក	ហ៊ីង សារិន	អភិបាលរងខេត្តកំពង់ឆ្នាំង	សមាជិក
២១-	លោក	អោភ មុន្នី	អភិបាលរងខេត្តពោធិសាត់	សមាជិក
២២-	លោក	ស៊ូ អាំហ្វាត់	អភិបាលរងខេត្តបាត់ដំបង	សមាជិក
២៣-	លោក	ហោ សារុន	អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍	សមាជិក
២៤-	លោក	ទី សារ៉ាន	អគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ នៃ ក្រសួងពត៌មាន	សមាជិក
២៥-	ឧត្តមសេនីយ៍	យុន ឈុន្នី	ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃក្រសួងមហាផ្ទៃ	សមាជិក
២៦-	ឧត្តមសេនីយ៍	គៀត ច័ន្ទថារិទ្ធ	ប្រធាននាយកដ្ឋាននគរបាលជនបរទេសនៃក្រសួងមហាផ្ទៃ	សមាជិក
២៧-	ឧត្តមសេនីយ៍	ស៊ុន ប៊ុនសក្តិ	តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
២៨-	លោក	ប៉ាក់ សុខុម	ប្រធាននាយកដ្ឋានផ្សព្វផ្សាយ និងសិក្សាទីផ្សារ នៃក្រសួងទេសចរណ៍	សមាជិក
២៩-	លោក	ឈុន ណាក់	អនុប្រធាននាយកដ្ឋានអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងទេសចរណ៍	សមាជិក

៣០-	ឧត្តមសេនីយ៍ ថន អ៊ឹម	អនុប្រធានទី ១ នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់ សាធារណៈ នៃក្រសួងមហាផ្ទៃ	សមាជិក
៣១-	លោក វ៉ាន់ ថន	នាយករង នាយកដ្ឋានរដ្ឋបាលនៃក្រសួងសាធារណៈការ និងដឹកជញ្ជូន	សមាជិក
៣២-	លោក ហូ វណ្ណី	ប្រធានទីភ្នាក់ងារទេសចរណ៍កម្ពុជា	សមាជិក
៣៣-	លោក ហូ គ្រីស	ប្រធានសមាគមសណ្ឋាគារកម្ពុជា	សមាជិក

ប្រការ ២.-

ក្រុមការងាររៀបចំក្បួនរថយន្ត Caravan Tours ពីបាងកក-ភ្នំពេញ-ហូជីមិញ មានមុខងារ និងភារកិច្ចដូចតទៅ:

- រៀបចំបដិសណ្ឋារកិច្ច ស្វាគមន៍ដល់គណៈប្រតិភូក្រុមកីឡាករក្បួនរថយន្ត Caravan Tour នៅតាមបណ្តាខេត្ត-ក្រុងដែលឆ្លងកាត់ ជាពិសេសនៅច្រកទ្វារព្រំដែនអន្តរជាតិចូលប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងតាមបណ្តាខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តព្រៃវែង ចេញតាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ខេត្តស្វាយរៀង និងត្រលប់មកវិញតាមបណ្តាខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ហើយចេញតាមច្រកទ្វារប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- ត្រូវរៀបចំពិធីជប់លៀងអាហារពេលល្ងាចជាផ្លូវការ ស្វាគមន៍ដល់គណៈប្រតិភូ និងក្រុមកីឡាករនៅខេត្តសៀមរាប
- សហការទំនាក់ទំនងជាមួយស្ថានទូតថៃ-វៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សា និងដោះស្រាយរាល់ការងារដែលពាក់ព័ន្ធ ក្នុងកិច្ចដំណើរការរៀបចំក្បួនរថយន្ត Caravan Tour ឱ្យមានភាពរលូន
- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អ ក្នុងពេលក្បួនរថយន្ត Caravan Tour នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើការផ្សព្វផ្សាយតាមបណ្តាញព័ត៌មាន ជាពិសេសតាមវិទ្យុ ទូរទស្សន៍ ដើម្បីឱ្យសាធារណជនបានយល់ដឹងជ្រួតជ្រាប និងចូលរួមក្នុងពិធីនេះ
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ព្រមទាំងមានសិទ្ធិស្វែងរក ទទួលជំនួយ និងការឧបត្ថម្ភនានា ដល់កិច្ចដំណើរការនៃពិធីនេះ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការរៀបចំ និងកិច្ចដំណើរការនៃពិធីនេះជូនប្រមុខរាជរដ្ឋាភិបាល

ប្រការ ៣.-

ក្រុមការងារនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍ និងមានសមាសភាព:

១-	លោក	ហោ សារុន	អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍	ប្រធាន
២-	លោក	ប៉ាក់ សុខុម	ប្រធាននាយកដ្ឋានផ្សព្វផ្សាយ និងសិក្សាទីផ្សារនៃក្រសួងទេសចរណ៍	អនុប្រធាន
៣-	លោក	ឈុន ណាក់	អនុប្រធាននាយកដ្ឋានអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងទេសចរណ៍	សមាជិកអចិន្ត្រៃយ៍
៤-	លោក	ហេង បុណ្ណា	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍	លេខាធិការ
៥-	លោក	សំ វុទ្ធា	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍	សមាជិក
៦-	លោក	គង់ សូលីដា	អនុប្រធាននាយកដ្ឋានអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងទេសចរណ៍	សមាជិក
៧-	លោក	ផ្លុង ធឿន	អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយ និងសិក្សាទីផ្សារនៃក្រសួងទេសចរណ៍	សមាជិក
៨-	លោក	សុង តុងហាប់	អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍	សមាជិក
៩-	លោក	ជង់ ឡឹម	ប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ	សមាជិក
១០-	លោក	កុយ សង	ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប	សមាជិក
១១-	លោក	ផៃ ដារ៉ារិទ្ធ	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំ	សមាជិក
១២-	លោក	ប៉ុង យ៉េន	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ចាម	សមាជិក
១៣-	លោក	ពៅ សាខន	ប្រធានមន្ទីរទេសចរណ៍ខេត្តកណ្តាល	សមាជិក
១៤-	លោក	ចិន សាម៉ន	ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ	សមាជិក
១៥-	លោក	អេង ប៉ាក់	ប្រធានមន្ទីរទេសចរណ៍ខេត្តព្រៃវែង	សមាជិក
១៦-	លោក	អ៊ុន ហួន	ប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរៀង	សមាជិក
១៧-	លោក	ស៊ីវ រុន	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង	សមាជិក
១៨-	លោក	ញ៉ូវ សុង	ប្រធានមន្ទីរទេសចរណ៍ខេត្តពោធិសាត់	សមាជិក
១៩-	លោក	ម៉ក់ ស៊ីនណារ៉ា	ប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង	សមាជិក
២០-	លោក	ពេញ ពន្លក	នាយការិយាល័យគណនេយ្យ នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍	សមាជិក សមាជិក
២១-	លោក	កែវ វាសនា	នាយការិយាល័យសរុបនៃនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ	

			ក្រសួងទេសចរណ៍	លេខាកត់ត្រា
២២-	លោក	ឆឹង មុន្នី	នាយការិយាល័យស្ថានតំណាង នៃនាយកដ្ឋានផ្សព្វផ្សាយ និងសិក្សាទីផ្សារ ក្រសួងទេសចរណ៍	លេខាកត់ត្រា
២៣-	លោក	ស៊ឹង សុណាត	មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅក្រសួងទេសចរណ៍	សមាជិក

ប្រការ ៤.-

- ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍ក្នុងការបំពេញការងារ ។
- សមាជិកនៃក្រុមការងារនេះត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៥.-

ក្រុមការងារនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច ។

ប្រការ ៦.-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី នៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ខាងលើ ត្រូវទទួលអនុវត្តសេចក្ដីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦ ស.ស.រ

សេចក្តីសម្រេច

ស្តីពី

ការកែសម្រួលប្រការ២ នៃសេចក្តីសម្រេចលេខ ៧៧ សសរ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំណុចការងារសម្រាប់តាមដានរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៧៧ សសរ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំណុចការងារសំរាប់តាមដានរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- យោងតាមតម្រូវការចាំបាច់

សម្រេច

ប្រការមួយ ..

ត្រូវបានកែសម្រួលប្រការ២ នៃសេចក្តីសម្រេចលេខ ៧៧ សសរ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំណុចការងារសម្រាប់តាមដានរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដូចតទៅ :

ប្រការ២ថ្មី .-

ចំណុចការងារនេះមានសមាសភាព ដូចតទៅ :

- ឯកឧត្តម **ម៉ុន អ៊ុយ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- ឯកឧត្តម **នីយ ចើន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល អនុប្រធាន
- ឯកឧត្តម **សេន សុវណ្ណ** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សៅ ចាញ់ អនុប្រធាន
- ឯកឧត្តម **ជួង លឿង** មេធាវីរាជរដ្ឋាភិបាល សមាជិក
- ឯកឧត្តម **លី ស៊ីវណ្ណា** អគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក
- ឯកឧត្តម **ខៀវ ឆេន** ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី សៅ ចាញ់ សមាជិក
- លោក **ឡុង សុខា** ប្រធាននាយកដ្ឋានកសិកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- លោក **ឯម តិរម្យ** អនុប្រធាននាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- លោក **ទីវ៉ន់ មុនីសុវណ្ណ** ប្រធានការិយាល័យចំណុចការងារតាមដានឃ្លាំមើលរបាយការណ៍ព្រៃឈើនៃនាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី ជាលេខាធិការ

ប្រការពីរ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការបី .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ២ថ្មី ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ១០ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៤៧...សសរ

សេចក្តីសម្រេច

ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤-ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រ េ ច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅចូលរួមចូលរួមពិធីបើកសន្និសីទកំពូលពុទ្ធសាសនាពិភពលោកលើកទី៤ និងកិច្ចប្រជុំកំពូលលើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច កម្ពុជា ឡាវ-មីយ៉ាន់ម៉ា-ថៃ និងវៀតណាម (ACMECS) ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ចាប់ពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៥ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៥៧ សហវ.

ប្រកាសអន្តរក្រសួង
ស្តីពី
ការអនុញ្ញាតឱ្យសេវាសុខាភិបាលអនុវត្ត ការពិនិត្យ និងព្យាបាលជំងឺដោយ យកកំរៃខ្លះពីអ្នកជំងឺ

រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ៥/សរកម/០៧០៤/០០១ ចុះថ្ងៃទី ១៣-០៧-២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំរាប់ធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ចុះថ្ងៃទី ១៥-០៧-២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល ។
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- អនុវត្តតាមសេចក្តីជូនដំណឹងលេខ ១២៩១ ស.ជ.ណ.អ.រ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការឯកភាពជាគោលការណ៍ ឱ្យមន្ទីរពេទ្យរដ្ឋ ថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង និងថ្នាក់ស្រុក រៀបចំផ្នែកពិនិត្យ និង ព្យាបាលជំងឺយកកំរៃពីអ្នកជំងឺខ្លះ១ ។

សម្រេច

ប្រការ ១ : ត្រូវបានអនុញ្ញាតឱ្យផ្នែកសេវាសុខាភិបាល រៀបចំការបង្កើតការពិនិត្យ និង ព្យាបាលជំងឺ យកកំរៃពីអ្នកជំងឺ តាមមន្ទីរពេទ្យថ្នាក់កណ្ដាល មន្ទីរពេទ្យបង្អែកខេត្ត-ស្រុក និង មណ្ឌលសុខភាព ។

ប្រការ ២ : សេវាដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមគោលនយោបាយសុខាភិបាល ដោយត្រូវយកចិត្តទុកដាក់ថែទាំអ្នកជំងឺ គោរពសីលធម៌ វិជ្ជាជីវៈ ក្នុងស្មារតី មនុស្សធម៌ ទូលំទូលាយ រក្សាបាននូវគុណភាពសេវា និង មិនយកថ្លៃពីអ្នកជំងឺក្រីក្រ ។

ប្រការ ៣ : ការកំណត់គិតកំរៃដែលត្រូវយកពីអ្នកជំងឺ អាស្រ័យដោយគណៈកម្មការមួយដែលមានតំណាងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ តំណាងក្រសួងសុខាភិបាល និង អង្គភាព រៀបចំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល សំរាប់អង្គភាពថ្នាក់កណ្ដាល ។

ចំពោះអង្គភាពខេត្ត-ក្រុង ស្រុក និង មណ្ឌលសុខភាព អាស្រ័យដោយគណៈកម្មការមួយដែលមានតំណាងសហគមន៍ តំណាងមន្ទីរហិរញ្ញវត្ថុ និង ប្រធានសាមីអង្គភាព រៀបចំដោយមន្ទីរសុខាភិបាលខេត្ត-ក្រុង រឺ គណៈកម្មការអភិវឌ្ឍន៍ស្រុក ឃុំ ។

ប្រការ ៤ : ថវិកាដែលប្រមូលបានពីអ្នកជំងឺ ត្រូវគ្រប់គ្រង និង ចាត់ចែងដូចខាងក្រោមនេះ :

- ៣៩% សំរាប់ជំនួយបង្កើនគុណភាពសេវាកម្ម
- ៦០% សំរាប់ចំណាយឧបត្ថម្ភមន្ត្រីរាជការ និយោជិក
- ១ % សំរាប់បង់ចូលថវិកាជាតិ ។

ដោយឡែកចំណូលផ្សេងៗទៀតក្រៅពីចំណូលខាងលើត្រូវបង់ចូលថវិការដ្ឋ ៧៥% និង ២៥% សំរាប់ជំនួយបង្កើនគុណភាពសេវាកម្ម ។

ប្រការ ៥ : ដើម្បីឱ្យមានតម្លាភាពក្នុងការប្រើប្រាស់ប្រាក់ចំណូលនេះ គណៈកម្មាការហិរញ្ញប្បទាននិងអង្គភាព ត្រូវធ្វើរបាយការណ៍ចំណូលចំណាយ ជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយបានជាប្រចាំរៀងរាល់ ត្រីមាស និងប្រចាំឆ្នាំ ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកបច្ចេកទេសសុខាភិបាលប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ប្រធានមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក ប្រធានមណ្ឌលសុខភាព អង្គភាពពាក់ព័ន្ធទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួងសុខាភិបាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភារៈកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០៥

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វជ្ជ. នុត សុខុម

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋលេខាធិការ

គង់ វិបុល

ចំលងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង

  " ដើម្បីជូនជ្រាប "
- ដូចប្រការ៧ " ដើម្បីអនុវត្ត "
- ឯកសារ និង កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៩២ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០០៥

ប្រកាស
ស្តីពី
ការកែសំរួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យ និង វាយតំលៃ លើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រដោយសារ គំរោងការអភិវឌ្ឍន៍ ទេសចរណ៍ មេគង្គ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ: ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ:នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤
- ប្រកាសលេខ ១៥១ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៤

សំរេច

ប្រការ ១ : កែសំរួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតំលៃលើផលប៉ះពាល់សំណង់ផ្ទះសម្បែង ដីធ្លី និងទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជារាស្ត្រក្នុងគំរោងការអភិវឌ្ឍន៍ ទេសចរណ៍ មេគង្គ ។

ប្រការ ២ : គណៈកម្មការអន្តរក្រសួងនេះ ត្រូវបានកែសំរួលសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២. ឯកឧត្តម **ទៀ ចិស្សុត** អគ្គលេខាធិការរង នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣. ឯកឧត្តម **ស្តួត សំបូរ** អគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៤. លោក ឆិត ចន្ថា	អគ្គនាយករងទេសចរណ៍ នៃ ក្រសួងទេសចរណ៍	សមាជិក
៥. លោក ហ៊ុយ ណារ៉ា	អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៦. លោក សេខ ទារ៉ុន្នី	ប្រធាននាយកដ្ឋានរដ្ឋបាល នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	សមាជិក
៧. លោក ស៊ សារឿន	អនុប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨. លោកបណ្ឌិត ឈន សុភាព	ប្រធានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៩. លោក ជូ ទារ៉ង់នី	អនុប្រធានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១០.លោក ចារ់ ប៊ុណ្ណារិទ្ធ	អនុប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១១.លោក ហ៊ីទ បញ្ញាឧត្តម	ប្រធានផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ នៃ អង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១២.លោក ស៊ុន សុខនី	ប្រធានផ្នែកគំរោង ADB និង WB នៃអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក

ប្រការ ៣ : គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះទៅពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិលើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លីរបស់ប្រជារាស្ត្រ រួចធ្វើការវាយតម្លៃអោយបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចនូវថវិកាមួយចំនួនជាគោលនយោបាយជូនដល់ប្រជារាស្ត្រវិញ ។

ប្រការ ៤ : គណៈកម្មការនេះ មានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការផ្ទាល់ និង មានសិទ្ធិស្នើសុំបង្កើតក្រុមការងារមួយដែលមានសមាសភាពមន្ត្រីជំនាញពាក់ព័ន្ធ សំរាប់បំពេញការងារប្រចាំថ្ងៃ ។

ប្រការ ៥ : ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់, ក្រសួងទេសចរណ៍, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ , នាយកដ្ឋានទ្រព្យរដ្ឋ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៤០ សហវ.ប្រកា.ពន្ធ

ប្រកាស
ស្តីពី
ការបែងចែកប្រាក់រង្វាន់នៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញប្រកាសលេខ ០០៤ ប្រក/សហវ/ពជ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០១ ស្តីពីការផ្តល់រង្វាន់ជូនអង្គភាពពន្ធដារ

- បានឃើញប្រកាសលេខ ២៨៧ សហវ/ពជ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបែងចែកប្រាក់រង្វាន់របស់អង្គភាពពន្ធដារ
- បានឃើញប្រកាសលេខ ២៧០ សហវ/ប្រក ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៥ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៥
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០០៥

សំរេច

ប្រការ ១ : ចាប់ពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០០៥តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលមិនបានបង់ពន្ធសំរាប់ឆ្នាំ២០០៥ ដូចបានកំណត់ក្នុងប្រការ ១ នៃប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ២០០៥ ។

ប្រាក់ពិន័យដែលទទួលបានមកអំពីការពិន័យលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥ ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

ក-ប្រាក់ពិន័យដែលទទួលបានក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ *(នៅទីចំណតនានា)* ដែលមានសហការរវាងមន្ត្រីពន្ធដារ និង មន្ត្រីមានសមត្ថកិច្ចដែលបានចូលរួម ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

១- ៥០% (ហាសិបភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

២- ៥០% (ហាសិបភាគរយ) ត្រូវបានអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់ដូចតទៅ :

- ១៥% (ដប់ប្រាំភាគរយ) បង់ចូលនាយកដ្ឋានពន្ធដារ
- ៣៥%(សាមសិបប្រាំភាគរយ)សំរាប់បែងចែកដូចខាងក្រោម :
  - + ៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ។
  - + ២០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាខាពន្ធដារខេត្ត-ក្រុង ។
  - + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខេត្ត-ក្រុង ។
  - + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខ័ណ្ឌ-ស្រុក ។

ខ-ប្រាក់ពិន័យដែលទទួលបានក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ *(នៅក្នុង ភូមិ ឃុំ-សង្កាត់)* ដែលមានសហការរវាងមន្ត្រីពន្ធដារ នគរបាលឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលបានចូលរួម ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

១- ៥០% (ហាសិបភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

២- ៥០% (ហាសិបភាគរយ) ត្រូវបានអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់ដូចតទៅ :

- ១៥% (ដប់ប្រាំភាគរយ) បង់ចូលនាយកដ្ឋានពន្ធដារ
- ៣៥%(សាមសិបប្រាំភាគរយ)សំរាប់បែងចែកដូចខាងក្រោម :
    + ៥០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ។
    + ២០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាខាពន្ធដារខេត្ត-ក្រុង ។
    + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខេត្ត-ក្រុង ។
    + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខ័ណ្ឌ-ស្រុក ។
    + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

ប្រការ ២ : អនុញ្ញាតឱ្យសាខាពន្ធដារខេត្ត-ក្រុងនីមួយៗ ដកប្រាក់រង្វាន់ពីការផាកពិន័យពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥នេះភ្លាមសំរាប់បែងចែកជូនសមាជិកក្រុមត្រួតពិនិត្យនិងអង្គភាព តាមសមាមាត្រដូចបានចែងក្នុងប្រការ១ខាងលើ ហើយត្រូវធ្វើរបាយការណ៍បូកសរុបពីស្ថានភាពចំណូល និង ចំណាយបេឡាប្រាក់រង្វាន់ជូននាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យ និង សំរេចទូទាត់ជាក្រោយ ។

ប្រការ ៣ : ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ តុលា ឆ្នាំ២០០៥

គាត ឈន់

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជារបាយការណ៍"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
    "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
    "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ........៦៩៦.....សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

ប្រកាស
ស្តីពី
ការបង្កើតគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកត/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/០៤ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និ ងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញបទបញ្ជាលេខ ៣០ បប ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសារាចរណែនាំលេខ ០១៦ សរ.សហវ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីថែរក្សាទ្រព្យសម្បត្តិរដ្ឋ និង ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩
- បានឃើញបទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល
- បានឃើញចំណាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤
- យោងការផ្លាស់ប្តូរភារកិច្ចមន្ត្រី ចំនួន០២រូប មន្ត្រីចូលនិវត្តន៍ចំនួន ០២រូប នៃប្រកាសលេខ ៩១០ សហវ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០១ និងបំពេញបន្ថែមមន្ត្រីជាសមាជិកគណៈកម្មការ ចំនួន ០២រូប
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ : បង្កើតគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ញាណ ឡេង	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ប្រធាន
២-លោក ឃុត សាខន	ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ	អនុប្រធាន
៣- លោក នេត មុន្នី	ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ	អនុប្រធាន
៤- លោក វង្ស ដាវី	ប្រធានការិយាល័យនីតិកម្មហិរញ្ញវត្ថុ នៃនាយកដ្ឋាននីតិកម្ម	សមាជិកអចិន្ត្រៃយ៍ ✓
៥- លោក លីវ ប៊ុនហៃ	ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន	សមាជិក
៦- លោក ឡាយ ឫទ្ធី	នាយករងទីចាត់ការគយ និង រដ្ឋាករ	សមាជិក
៧- លោក ម៉ី រិន	អនុប្រធានរតនាគារជាតិ	សមាជិក
៨- លោក វង្ស វ៉ូដាវុឌ្ឍ	អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ	សមាជិក
៩- លោក ចាន់ ស៊ុ	អនុប្រធាននាយកដ្ឋានពន្ធដារ	សមាជិក
១០- លោក គុយ សាវុធ	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិក
១១-លោក មាស ចាន់ដេត	ប្រធានការិយាល័យគណនេយ្យនៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិក
១២-លោក ហែម ស៊ីវន	ប្រធានការិយាល័យសារពើភ័ណ្ឌ នៃនាយកដ្ឋាទ្រព្យសម្បត្តិរដ្ឋ	សមាជិក
១៣-លោក ម៉ុក ស៊ីថា	ប្រធានការិយាល័យត្រួតពិនិត្យ នៃនាយកដ្ឋានបុគ្គលិក	សមាជិក
១៤-លោក ម៉ែន ណារុន	អនុប្រធានការិយាល័យសារពើភ័ណ្ឌ នៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ	សមាជិក
១៥- លោក ហេង សុខ័ណ្ឌ	មន្ត្រីនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិក
១៦- លោក ហ៊ុន ពិសិដ្ឋ	មន្ត្រីនាយកដ្ឋាននីតិកម្ម	លេខាធិការ និងជាការីកុំព្យូទ័រ ✓

ប្រការ២ : គណៈកម្មការនេះមានភារកិច្ច :

- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ប្រចាំឆ្នាំនូវបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពនៅថ្នាក់កណ្តាលចំណុះទីស្តីការក្រសួង និងមន្ទីរ-អង្គភាពជំនាញនៅតាមខេត្ត-ក្រុង ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ទោះបីធ្វើអាជីវកម្ម ឬ ប្រើប្រាស់ជាផលប្រយោជន៍រួមក៏ដោយព្រមទាំងកត់ត្រាឱ្យបានច្បាស់លាស់អំពីចំនួនកើន និង ចំនួនថយ ដោយប្រការផ្សេងៗដូចជា ដីធ្លី អគារ សម្ភារៈបរិក្ខារ....ដែលអាជ្ញាធរដែនដី អង្គការអន្តរជាតិនានា សប្បុរសជនជាតិ និង អន្តរជាតិប្រគល់ឱ្យកន្លងមក លទ្ធផលនៃការប្រើប្រាស់ឥណទានសំរាប់ទិញដី ការកសាងថ្មី ជួសជុលអគារ សម្ភារៈបរិក្ខារ បច្ចេកទេសឧស្សាហកម្ម ការប្រើប្រាស់ឥណទានជំពូក ១១ កង់ខ័ណ្ឌ២ និង ការប្រើប្រាស់ប្រាក់រង្វាន់ ។ ល។ ដើម្បីកត់ត្រាចូលក្នុងបញ្ជីសារពើភ័ណ្ឌជាទ្រព្យសម្បត្តិរដ្ឋ ។
- រាយការណ៍ជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីលទ្ធផលការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ អំពីចំនួនកើន និង ចំនួនថយទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពនៅថ្នាក់កណ្តាលចំណុះទីស្តីការក្រសួង និង មន្ទីរ-អង្គភាព ជំនាញនៅតាមខេត្ត-ក្រុង ព្រមទាំងលើកសំណើជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច :

+ អំពីករណីដីធ្លី ដែលទុកចោលទំនេរ និង ធ្វើការបែងចែកដីជូនអង្គភាពជំនាញហិរញ្ញវត្ថុ ខេត្ត-ក្រុង ដែលគ្មានទីតាំងរដ្ឋបាល ដើម្បីជៀសវាងប្រការចំណាយឥណទានរបស់ក្រសួងក្នុងការទិញដីថ្មីឡើយ ។

+ អគារ យានយន្ត គ្រឿងចក្រ និងសម្ភារៈ សង្ហារឹម ដែលអស់តម្លៃក្នុងការប្រើប្រាស់ត្រូវស្នើសុំគោលការណ៍ជំរះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

- ក្នុងករណីចាំបាច់ ឬ មានវិវាទកម្មផ្សេងៗ គណៈកម្មការនេះត្រូវធ្វើអង្កេតវាយតម្លៃទ្រព្យសម្បត្តិរដ្ឋ គ្រប់អង្គភាពនៅថ្នាក់ កណ្តាលចំណុះទីស្តីការក្រសួង និង មន្ទីរ-អង្គភាពជំនាញនៅតាមខេត្ត-ក្រុង ជាបន្ទាន់ដោយមិនបាច់ជូនដំណឹងជាមុនឡើយ ដើម្បីទប់ស្កាត់រាល់ចាតុកាព៌លោភបំពារបំពានយកទ្រព្យសម្បត្តិរដ្ឋ ។

ប្រការ៣ : រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលផ្ទុយនិងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤ : ឯកឧត្តមអគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ នាយកដ្ឋានពន្ធដារ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុគ្រប់ខេត្ត-ក្រុង អង្គភាពពាក់ព័ន្ធ ព្រមទាំងអស់លោកដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាស នេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :
ទីស្តីការគណៈរដ្ឋមន្ត្រី
គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋាន និងអង្គភាពចំណុះទីស្តីការក្រសួង
- ដូចប្រការ ៤
"ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°៧៧១ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣១៧៧/០៥ ត.រ.ក ចុះថ្ងៃទី១៥.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២២.០៩.២០០៥

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា)(WHITEX GARMENTS (CAMBODIA) CO., LTD.) តំណាងដោយ លោកស្រី LEE LI HEONG សញ្ជាតិម៉ាឡេស៊ី អាយុ៤៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ A10646501 ចុះថ្ងៃទី០២.០៨.២០០១ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "វ៉ាយថិច ហ្គាមេន (ខេមបូឌា) (WHITEX GARMENTS (CAMBODIA))" មានទីតាំងស្ថិតនៅភូមិត្រពាំងថ្នឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៥០១ ឧរថ.ករ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៧៣/០៥ ត.វ.ក ចុះថ្ងៃទី១៥.០២.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១៦១៥/០៥ ត.វ.ក ចុះថ្ងៃទី២០.០៥.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ីសធើន សាន់ ធីប៊ែកខូ ចុះថ្ងៃទី២៥.០៨.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីសធើន សាន់ ធីប៊ែកខូ (EASTERN SUN TOBACCO CO., LTD.) តំណាងដោយ លោក LIN QIN-MO សញ្ជាតិចិន(តៃវ៉ាន់) អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 130273979 ចុះថ្ងៃទី១៩.១០.២០០១ បង្កើតរោងចក្រ "ផលិតបារី" ដែលមានឈ្មោះថា "អ៊ីសធើន សាន់ ធីប៊ែកខូ (EASTERN SUN TOBACCO)" មានទីតាំងស្ថិតនៅ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣ .
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់អាគារ មកក្រសួងក្នុងរយៈពេល ៣ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតពារី" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន អ៊ីសចើន សាន់ ទីប៉ៃកខូ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៥៥ ឧ.ក.រ.ម (ប.ក)

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ១៧ ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស/ រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៣៥២/០៥ គ.វ.ក ចុះថ្ងៃទី២៩.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី០៦.០៦.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី (RAINBOW SCREEN PRINTING PTE LTD.) តំណាងដោយ លោក ANG BOON CHEOW, EDWARD សញ្ជាតិសិង្ហបុរី ភេទប្រុស អាយុ៤៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ S1205391F ចុះថ្ងៃទី២៩.០៤.១៩៩៧ បង្កើតរោងចក្រ "បោះពុម្ពសម្លៀកបំពាក់" ដែលមានឈ្មោះថា "រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី (RAINBOW SCREEN PRINTING PTE LTD.)" មានទីតាំងស្ថិតនៅ ផ្លូវចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ“ បោះពុម្ពសម្លៀកបំពាក់” ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឹងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១គ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

“ ដើម្បីជូនជ្រាប ”
- ដូចប្រការ៩ “ ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៨០៩ ឧរម.គឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣២៤៤/០៥ ត.វ.ក ចុះថ្ងៃទី២២.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន ចុះថ្ងៃទី០១.០៨.២០០៥

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន (SHUANG TU (CAMBODIA) MEDICAL EQUIPMENT CO., LTD.) តំណាងដោយ លោក LI ZHONGHUA សញ្ជាតិចិន អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G12246242 ចុះថ្ងៃទី០៨.០៥.២០០៥ បង្កើតរោងចក្រ "ផលិតសំភារៈ បរិក្ខារពេទ្យ" ដែលមានឈ្មោះថា " ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន (SHUANG TU (CAMBODIA) MEDICAL EQUIPMENT)" មានទីតាំងស្ថិតនៅអាគារលេខ១៨ នៃសួនឧស្សាហកម្មកាណាឌីយ៉ា ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតសំភារៈបរិក្ខារពេទ្យ" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខ រោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់១ឆ្នាំ ក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៨១០ ឧរថ. កឧ. ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០៥.

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣២៤៨/០៥ ក.វ.ក ចុះថ្ងៃទី២២.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ចាង តៃ អ៊ិនធើណេសិនណល ខប ចុះថ្ងៃទី១០.១០.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ចាង តៃ អ៊ិនធើណេសិនណល ខប (CHANG TAI INTERNATIONAL CORP.) តំណាងដោយ លោក YEH, MU SEN សញ្ជាតិចិន (តៃវ៉ាន់) អាយុ៣៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 200527214 ចុះថ្ងៃទី២៦.០៣.២០០៣ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ចាង តៃ អ៊ិនធើណេសិនណល ខប (CHANG TAI INTERNATIONAL CORP.) មានទីតាំងស្ថិតនៅ សួនឧស្សាហកម្មកាណាឌីយ៉ា អាគារលេខ C១១ និងលេខ២១ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសំលៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចូន់ចូរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ចាង តៃ អ៊ិនធើណេសិនណល ខប ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៤១១ ឧរម.កឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០៥

ប្រ ក ា ស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៣៤១/០៥ គ.វ.ក ចុះថ្ងៃទី២៨.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន ចុះថ្ងៃទី០៦.១០.២០០៥

ស ំ រ េ ច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន (MING HUI GARMENT CO., LTD.) តំណាងដោយលោក LI ZHONG MING សញ្ជាតិចិន អាយុ៤៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ PCHN 148366844 ចុះថ្ងៃទី ២០.០៧.២០០៤ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " មិញ ហ៊ុយ ហ្គាមេន (MING HUI GARMENT)"មានទីតាំងស្ថិតនៅ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខ រោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់១គ្នា ក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៤១៧ ឧសថ.ករ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣១៦៥/០៥ ត.វ.ក ចុះថ្ងៃទី១៤.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ឌី អឹម អេ (ខេមបូឌា) ចុះថ្ងៃទី១៩.០៧.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ឌី អឹម អេ (ខេមបូឌា) (DMA (CAMBODIA) CO.,LTD.) តំណាងដោយលោក MAO JINQUAN សញ្ជាតិ ចិន អាយុ៤១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G05511285 ចុះថ្ងៃទី២១.១១.២០០២ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ "ដែលមានឈ្មោះថា "ឌី អឹម អេ (ខេមបូឌា) (DMA (CAMBODIA) LTD.) " មានទីតាំងស្ថិតនៅ បន្ទាយC7 ភូមិដំណាក់ធំ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ “កាត់ដេរសម្លៀកបំពាក់” ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ឌី អឹម អេ (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ
“ ដើម្បីជូនជ្រាប ”
- ដូចប្រការ ៩ “ ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ ១៤៣៣ ប្រ.ក

ប្រកាស
ស្តីពី
ការប្រើប្រាស់ផ្លាកលេខថ្មីសំគាល់យានជំនិះ និងជលយាននគរបាលជាតិ និងការគ្រប់គ្រងបញ្ជីប័ណ្ណសំគាល់យានជំនិះគ្រប់ប្រភេទ

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ៦៨ ក្រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីចរាចរផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការចេញផ្លាកលេខ សំគាល់យានជំនិះ
- តាមសំណើរបស់អគ្គស្នងការនគរបាលជាតិ

សំរេច

ប្រការ ១ កំណត់ទូទៅ

១.១. ប្រគល់សិទ្ធិជូន អគ្គស្នងការនគរបាលជាតិ រៀបចំផ្លាស់ប្តូរប័ណ្ណសំគាល់ និងចេញផ្លាកលេខថ្មី យានយន្តនិងជលយានជាកម្មសិទ្ធិរបស់ក្រសួងមហាផ្ទៃ ប្រើប្រាស់ជាមធ្យោបាយ សំរាប់ការងារ ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម និងត្រូវបូកសរុបរាយការណ៍ជូនក្រសួង ជារៀងរាល់ខែ ។

១.២. យានយន្តគ្រប់ប្រភេទ ដែលជាកម្មសិទ្ធិរបស់ក្រសួងមហាផ្ទៃរួមមាន រដ្ឋបំពាក់ ក្រសួងចំណាយថវិកាទិញផ្ទាល់ អំណោយពីអង្គការនានា និងសប្បុរសជន ហើយត្រូវបានចុះបញ្ជីសារពើភ័ណ្ឌនៅក្រសួងមហាផ្ទៃ ។

១.៣ យានយន្ត និងជលយាន ដែលត្រូវបានផ្តល់ប័ណ្ណសំគាល់ និង ផ្លាកលេខក្រសួងមហាផ្ទៃ ត្រូវបានបែងចែកប្រភេទដូចខាងក្រោម :

- ប្រភេទទី ១. ទោចក្រយានយន្ត និងត្រីចក្រយានយន្ត
- ប្រភេទទី ២. រថយន្តធុនតូច (ទេសចរណ៍)
- ប្រភេទទី ៣. រថយន្តធុន មធ្យម ធ្ងន់ យានយន្តឧបករណ៍ និងប្រយុទ្ធ
- ប្រភេទទី ៤. រ៉ឺម៉ក - សឺមីរ៉ឺម៉ក (យានសំរាប់ផ្ទុកជាប់ក្បាលរថយន្តសណ្តោង)
- ប្រភេទទី ៥. ជលយាន

ប្រការ ២. រូបភាពផ្លាកលេខ

២.១. ផ្លាកលេខយានយន្តមាន ៤ ប្រភេទ និងផ្លាកលេខជលយានមាន ១ ប្រភេទ មានទំហំ មានអក្សរដើមជាអក្សរខ្មែរ មានលេខកូដ លេខសំគាល់ អក្សរឡាតាំង ពណ៌ សញ្ញាសំគាល់ ដូចខាងក្រោម :

ក ១. ផ្លាកលេខសំរាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្ត

" **នគរបាល 1.0001 POLICE** "

ក ២. ផ្លាកលេខសំរាប់រថយន្តធុនតូច (ទេសចរណ៍)

" **នគរបាល 2.0001 POLICE** "

ក ៣. ផ្លាកលេខសំរាប់រថយន្តធុនមធ្យម ធ្ងន់ យានយន្តឧបករណ៍ និងប្រយុទ្ធ

" **នគរបាល 3.0001 POLICE** "

ក ៤. ផ្លាកលេខសំរាប់ រ៉ឺម៉ក-សឺមីរ៉ឺម៉ក (យានសំរាប់ផ្ទុកជាប់ក្បាលរថយន្តសណ្តោង)

" **នគរបាល 4.0001 POLICE** "

ក ៥., ផ្លាកលេខសំរាប់ជលយាន

" **នគរបាល 5.0001 POLICE** "

ខ **ទំហំផ្លាកលេខ :**

ខ ១. - ផ្លាកលេខទោចក្រយានយន្ត ត្រីចក្រយានយន្តទំហំ ២០០មម x ១២០មម

ខ ២. - ផ្លាកលេខរថយន្តធុនតូច (ទេសចរណ៍) ខាងមុខ និងខាងក្រោយ ទំហំស្មើគ្នា ៣០៥មម x ១៦០មម

ខ ៣. - ផ្លាកលេខរថយន្តធុនមធ្យម ធុនធំ យានយន្តុប្បករណ៍ និងប្រយុទ្ធ រ៉ឺម៉ក-សឺមីរ៉ឺម៉ក ទំហំ :

- ផ្លាកមុខ ៣៦០មម x ១៩០មម
- ផ្លាកក្រោយ ៣៦០មម x ២២០មម

ខ ៤. - ផ្លាកលេខជលយានមានចំនួនពីរ មានទំហំប៉ុនគ្នា ៣៦០មម x ២២០មម ដាក់នៅសងខាងផ្នែកខាងក្រោមនៃជញ្ជាំងមុខមានកំពស់ពីគែមចំនួន ២០មម ។

គ. __តួអក្សរ__

គ ១. __អក្សរខ្មែរ__ :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្តកំពស់ ២២មម សង្កត់ផុស ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តុប្បករណ៍ និងប្រយុទ្ធ រ៉ឺម៉ក សឺមីរ៉ឺម៉ក និងជលយានកំពស់ ៤៥មម សង្កត់ផុស ។

គ ២. __អក្សរឡាតាំង__ :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត កំពស់ ៨មម ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តុប្បករណ៍ និងប្រយុទ្ធ សឺមីរ៉ឺម៉ក និង ជលយានកំពស់ ១២មម ។

ឃ. __កំពស់លេខ__ :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត កំពស់ ៤៥មម ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តុប្បករណ៍ និងប្រយុទ្ធ សឺមីរ៉ឺម៉ក និង ជលយាន កំពស់ ៧០មម ។

ង. __ពណ៌__ :

ផ្លាកលេខគ្រប់ប្រភេទនៃយានយន្ត និងជលយាននគរបាលជាតិ ជាកម្មសិទ្ធិរបស់ក្រសួង មហាផ្ទៃ មានផ្ទៃពណ៌ ស អក្សរនិងលេខពណ៌ក្រហម មានសញ្ញារាជសីហ៍សំគាល់ផ្នែកខាងស្តាំ ជ្រុងខាងលើនៃផ្លាក ។

ប្រការ ៣ : __ការទូទាត់លើតំលៃផ្លាកលេខ__

៣.១. សាមីអង្គភាពនីមួយៗដែលប្រើប្រាស់យានយន្តគ្រប់ប្រភេទចំណុះ អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃមកសុំធ្វើការចុះបញ្ជីផ្តល់ផ្លាកលេខត្រូវស្នើសុំថវិកាពីក្រសួងដោយខ្លួនឯង មកបង់អោយនាយកដ្ឋានជំនាញដើម្បីផលិតជូនតាមតំលៃដូចខាងក្រោម :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត តំលៃ ៤២.០០០ រៀល
- រថយន្តធុនតូច (ទេសចរណ៍) ផ្លាកលេខចំនួនពីរ (មុខក្រោយ) តំលៃ ៩២.៤០០រៀល
- រថយន្តធុនមធ្យម ធុនធ្ងន់ យានយន្តឧបករណ៍ និងប្រយុទ្ធ សីមីរ៉ឺម៉ក និងជលយានផ្លាក ចំនួនពីរ តំលៃ ១១៣.៤០០ រៀល ។
- រូបសញ្ញានគរបាលជាតិ (រាជសីហ៍) ចំនួនមួយតំលៃ ៣៧.៨០០ រៀល ។
- តំលៃខាងលើអាចមានការប្រែប្រួលនិងកំណត់ជាថ្មី តាមអត្រាឡើងចុះនៃវត្ថុធាតុដើម តាមសំណើរបស់អគ្គស្នងការនគរបាលជាតិ ។

<u>ប្រការ ៤.</u> <u>លក្ខណប្រើប្រាស់</u> :

៤.១. យានយន្ត និងជលយានគ្រប់ប្រភេទ ដែលបំរើអោយអង្គភាពនគរបាលជាតិ ក្នុងប្រភេទដឹកជញ្ជូនកងអង្គរក្ស សង្គ្រោះ បង្ការនិងពន្លត់អគ្គីភ័យ រក្សាសណ្តាប់ធ្នាប់សាធារណៈ រក្សាសណ្តាប់ធ្នាប់ចរាចរ បង្ការនិងបង្ក្រាបបទល្មើសក្រៅពីផ្លាកលេខដែលបានពាក់ ត្រូវមានរូបសញ្ញានគរបាលជាតិ(រាជសីហ៍) និងមានសរសេរឈ្មោះអង្គភាពប្រើប្រាស់ព្រមទាំងអក្សរឡាតាំង (POLICE) ពីខាងក្រៅជារង្វង់ស្វែងក្របីតាមទំហំសមស្របនៅទ្វារមុខទាំងសងខាងនៃយានយន្ត ។ យានយន្តនិងជលយានទាំងនេះត្រូវបានលាបពណ៌ពិសេស តាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

៤.២. ក្រសួងមហាផ្ទៃប្រគល់សិទ្ធិអោយអគ្គស្នងការដ្ឋាននគរបាលជាតិ កំណត់កាលបរិច្ឆេទនៃការផ្លាស់ប្តូរប័ណ្ណសំគាល់ ចេញផ្លាកលេខថ្មីដល់យានយន្តនិងជលយានគ្រប់ប្រភេទ ដូចបានកំណត់ក្នុងប្រការ ១ និង ធ្វើបទដ្ឋានផ្សេងៗទៀតតាមការចាំបាច់ ព្រមទាំងធ្វើការត្រួតពិនិត្យការអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ។

៤.៣. អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវជំរុញកិច្ចសហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងការពារជាតិអោយបានល្អនិងទាន់ពេលវេលា ក្នុងការប្រមូលពតិមានទិន្នន័យនៃការផ្តល់ប័ណ្ណសំគាល់យានយន្ត ជលយាននិងផ្លាកលេខ ដូចមានចែងក្នុងមាត្រា ៥ , មាត្រា ៦ នៃអនុក្រិត្យលេខ៧៧អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ដើម្បីបំរើដល់ការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ។

៤.៤. បណ្តានាយកដ្ឋាន អង្គភាពនានា ស្នងការដ្ឋាននគរបាលគ្រប់ ខេត្ត-ក្រុង ដែលមានបណ្តាមធ្យោបាយដូចបានរៀបរាប់ក្នុងប្រការ ១ ត្រូវធ្វើបែបបទដើម្បីស្នើសុំប័ណ្ណសំគាល់និងផ្លាកលេខយានយន្ត ជលយានតាមគំរូថ្មី ។

៤.៥ ជនណា ប្រើប្រាស់ប័ណ្ណសំគាល់ និងផ្លាកលេខនគរបាលក្លែងក្លាយនឹងត្រូវផ្តន្ទាទោសតាមច្បាប់ ជា

ធរមាន ។

ប្រការ ៥: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីខ្លឹមសារដូចមានចែងក្នុងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦: អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល អភិបាលខេត្ត-ក្រុង ប្រធាននាយកដ្ឋាន អង្គភាពចំណុះ និងស្នងការនគរបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានិងឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី...១០...ខែ...ឧសភា...ឆ្នាំ ២០០៥

ស ខេង

ចំលងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់ស្ថាប័នចំណុះក្រសួងមហាផ្ទៃ
- គ្រប់ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
